# ភិក្ខាបរម្បរជាតក




ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈណាមួយ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **សុខុមាលរូបំ ទិស្វា** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈនោះជាអ្នកមានសទ្ធានិងសេចក្តីជ្រះថ្លា តែងធ្វើមហាសក្ការៈដល់ព្រះតថាគត និងព្រះសង្ឃរតនៈជានិច្ច ។ ថ្ងៃមួយ គាត់គិតថា យើងកាលឲ្យខាទនីយៈនិងភោជនីយៈទាំងឡាយដ៏ប្រណីត និងសំពត់ដែលមានសាច់ល្អិត ដល់ព្រះតថាគត និងព្រះសង្ឃរតនៈ តែងធ្វើមហាសក្ការៈជានិច្ច ឥឡូវនេះ យើងនឹងធ្វើសូម្បីដល់ព្រះធម្មរតនៈ តើយើងគប្បីធ្វើសក្ការៈដល់ព្រះធម្មរតនៈ ដូចម្តេច ។ គាត់កាន់គ្រឿងសក្ការៈទាំងឡាយជាច្រើន

មានរបស់ក្រអូបនិងផ្កាកម្រងជាដើម ទៅវត្តជេតពន ថ្វាយបង្គំព្រះសាស្តា ហើយសួរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណាប្រាថ្នានឹងធ្វើសក្ការៈដល់ព្រះធម្មរតនៈ តើខ្ញុំព្រះករុណា គប្បីធ្វើសក្ការៈដល់ព្រះធម្មតរនៈដូចម្តេច ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងគាត់ថា បើអ្នកចង់ធ្វើសក្ការៈដល់ព្រះធម្មរតនៈ អ្នកចូរធ្វើសក្ការៈដល់អានន្ទដែលធម្មភណ្ឌាគារិកៈចុះ ។ កុដុម្ពិកៈនោះទទួលថា សាធុ ហើយនិមន្តព្រះថេរៈ ក្នុងថ្ងៃស្អែក នាំព្រះថេរៈទៅកាន់ផ្ទះរបស់ខ្លួនដោយសក្ការៈដ៏ធំ និមន្តព្រះថេរៈឲ្យគង់លើអាសនៈដែលមានតម្លៃថ្លៃ បូជាដោយគ្រឿងសក្ការៈទាំងឡាយមានរបស់ក្រអូបនិងកម្រងផ្កាជាដើម ថ្វាយភោជនដែលមានរសឆ្ងាញ់ផ្សេងៗ និងប្រគេនសំពត់សាដកដែលល្មមធ្វើចីវរ ៣ ។ ចំណែកព្រះថេរៈគិតថា សក្ការៈដែលកុដុម្ពិកៈធ្វើដល់ព្រះធម្មរតនៈនេះ មិនសមគួរដល់យើង សមគួរដល់ព្រះធម្មសេនាបតីដែលជាអគ្គសាវក គិតយ៉ាងនេះហើយ លោកនាំបិណ្ឌបាត និងសំពត់ទៅប្រគេនព្រះសារីបុត្តត្ថេរ ។ សូម្បីព្រះសារីបុត្រនោះ ក៏គិតថា សក្ការៈដែលព្រះអានន្ទធ្វើដល់ព្រះធម្មរតនៈនេះ សមគួរដល់ព្រះសម្មាសម្ពុទ្ធ ដែលព្រះធម្មស្សាមីប៉ុណ្ណោះ ដូច្នេះហើយ លោកក៏ថ្វាយដល់ព្រះទសពល ។ ព្រះសាស្តាមិនឃើញជនដទៃដែលខ្ពង់ខ្ពស់ប្រសើរជាព្រះអង្គ ទ្រង់ក៏សោយបិណ្ឌបាត និងទទួលសំពត់ចីវរនោះទៅ ។

ភិក្ខុទាំងឡាយញាំងកថាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ កុដុម្ពិកៈឈ្មោះនោះគិតថា យើងនឹងធ្វើសក្ការៈដល់ព្រះធម្មរតនៈ បានប្រគេនដល់ព្រះអានន្ទត្ថេរដែលជាធម្មភណ្ឌាគារិកៈ, ព្រះថេរៈគិតថា សក្ការៈនេះមិនសមគួរដល់យើង ដូច្នេះក៏ប្រគេនដល់ព្រះធម្មសេនាបតី សូម្បីព្រះធម្មសេនាបតីនោះគិតថា សក្ការៈនេះមិនសមគួរដល់យើង ដូច្នេះក៏បានថ្វាយដល់ព្រះទសពល, ព្រះតថាគតកាលមិនឃើញជនដទៃប្រសើរជាង ព្រោះភាពជាម្ចាស់នៃធម៌របស់ព្រះអង្គ ទ្រង់គិតថា សក្ការៈនោះសមគួរដល់យើងប៉ុណ្ណោះ ដូច្នេះទ្រង់ក៏

សោយបិណ្ឌបាតនោះ និងទទួលសំពត់ចីវរ, បិណ្ឌបាតនោះបានទៅ ដល់បាទមូលរបស់ព្រះធម្មស្សាមី ព្រោះព្រះអង្គជាអ្នកសមគួរ ដោយអាការយ៉ាងនេះ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយរឿងអ្វី? កាលភិក្ខុទាំងឡាយទូលថា ដោយរឿងឈ្មោះនេះ ហើយព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ ដែលបិណ្ឌបាតប្រព្រឹត្តទៅតៗគ្នារហូតដល់អ្នកសមគួរនោះ សូម្បីក្នុងកាលមុន កាលព្រះពុទ្ធមិនកើតឡើង ក៏បានប្រព្រឹត្តទៅហើយដូចគ្នាដែរ យ៉ាងនេះហើយ ទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តលះបង់អគតិធម៌ មិនធ្វើរាជធម៌ ១០ ឲ្យកម្រើកសោយរាជសម្បត្តិដោយធម៌ ក្នុងនគរពារាណសី ។ ការវិនិច្ឆ័យមិនមានដល់ព្រះអង្គ ហាក់ដូចជារបស់សូន្យ ។ ព្រះរាជាស្វែងរកទោសរបស់ខ្លួន កាលពិចារណាដល់ជនដែលនៅខាងក្នុងនិវេសន៍ មិនឃើញអ្នកពោលទោសរបស់ព្រះអង្គទាំងក្នុងបុរី ទាំងខាងក្នុងនគរ និងក្នុងទ្វារស្រុក ព្រះអង្គគិតថា យើងនឹងស្វែងរកក្នុងជនបទ ហើយទ្រង់ប្រគល់រាជសម្បត្តិដល់ពួកអាមាត្យ យាងទៅក្នុងកាសិរដ្ឋ ដោយភេទមិនមានគេស្គាល់ មួយអន្លើដោយបុរោហិត ទ្រង់មិនឃើញអ្នកពោលទោសយ៉ាងណាមួយ ស្តេចយាងដល់និគមមួយ ក្នុងបច្ចន្តគ្រាម ហើយគង់នៅក្នុងសាលាមួយដែលនៅខាងក្រៅទ្វារស្រុក ។ ក្នុងខណៈនោះ មានកុដុម្ពិកៈដែលមានទ្រព្យ ៨០ កោដិ កាលទៅកំពង់មុជទឹកដោយបរិវារដ៏ធំ បានឃើញព្រះរាជាដែលមានសរីរៈជាសុខមានពណ៌សម្បុរដូចមាស អង្គុយនៅក្នុងសាលា គាត់ក៏កើតសេចក្តីស្រឡាញ់ចូលចិត្ត បានចូលទៅកាន់សាលា ធ្វើបដិសណ្ឋារៈ ហើយពោលថា សូមព្រះអង្គគង់នៅក្នុងទីនេះចុះ ដូច្នេះគាត់ក៏ទៅកាន់ផ្ទះ ចាត់ចែងភោជនដែលរសផ្សេងៗ ឲ្យគេកាន់យកភោជន រួចធ្វើដំណើរទៅដោយបរិវារដ៏ធំ ។ ក្នុងខណៈនោះ មានតាបសដែលបានអភិញ្ញា ៥ ដែលរស់នៅ

ក្នុងព្រៃហិមពាន្ត មកហើយ អង្គុយក្នុងសាលានោះ ។ សូម្បីព្រះបច្ចេកពុទ្ធ មកអំពីញកភ្នំនន្ទមូលក៍ ហើយគង់នៅក្នុងសាលានោះដែរ ។

កុដុម្ពិកៈថ្វាយទឹកលាងដៃដល់ព្រះរាជា និងចាត់ចែងភាជនៈភត្ត ដោយសម្ទនិងម្ហូបគ្រឿមដែលមានរសផ្សេងៗ នាំចូលទៅថ្វាយដល់ព្រះរាជា ។ ព្រះរាជាកាន់យកហើយ ក៏ប្រទានដល់ព្រាហ្មណ៍បុរោហិត ។ ព្រាហ្មណ៍បុរោហិតទទួលហើយ ក៏ថ្វាយដល់តាបស ។ តាបស (ទទួលហើយ) ទៅកាន់សម្នាក់ព្រះបច្ចេកពុទ្ធ កាន់ភាជនៈភត្តដោយដៃឆ្វេង កាន់កុណ្ឌីទឹកដោយដៃស្តាំង ថ្វាយទក្ខិណោទក ហើយដាក់ភត្តទៅក្នុងបាត្រ ។ ព្រះបច្ចេកពុទ្ធមិនអញ្ជើញអ្នកណា មិនហៅអ្នកណាឡើយ ក៏សោយបិណ្ឌបាតនោះទៅ ។ ក្នុងកាលដែលព្រះបច្ចេកពុទ្ធធ្វើភត្តកិច្ចហើយ កុដុម្ពិកៈគិតថា ភត្តគឺយើងថ្វាយហើយដល់ព្រះរាជា, ព្រះរាជាប្រទានដល់ព្រាហ្មណ៍បុរោហិត, ព្រាហ្មណ៍បុរោហិតថ្វាយដល់តាបស, តាបសថ្វាយដល់ព្រះបច្ចេកពុទ្ធ, ព្រះបច្ចេកពុទ្ធមិនហៅអ្នកណាមួយឡើយក៏ឆាន់ភត្តនោះទៅ អ្វីហ្ន៎ជាហេតុនៃទានរបស់ជនទាំងនេះ អ្វីហ្ន៎ជាហេតុនៃការឆាន់ របស់ព្រះបច្ចេកពុទ្ធនេះ ដែលមិនហៅអ្នកណាមួយ យើងនឹងសួរជនទាំងនោះ ។ កុដុម្ពិកៈនោះ ចូរទៅកាន់ជននីមួយៗ ថ្វាយបង្គំហើយសួរ ។ សូម្បីជនទាំងឡាយនោះ ក៏បានពោលដល់គាត់ ។

(កុដុម្ពិកៈទូលថា)

សុខុមាលរូបំ ទិស្វា, រដ្ឋា វិវនមាគតំ,
កុដាគារវរូបេតំ, មហាសយនមុបាសិតំ។

ខ្ញុំព្រះអង្គបានឃើញព្រះអង្គ មានព្រះរូបទន់ភ្លន់ ចេញចាកដែនមកកាន់ព្រៃស្ងាត់ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈដ៏ថ្លៃថ្លា ដែលគេក្រាលបម្រុងទុក ។

តស្ស តេ បេមកោជាហំ, អទាសឹ វឡ្លមោទនំ;
សាលីនំ វិចិតំ កត្តំ, សុចឹ មំសូបសេចនំ។

*ទើបថ្វាយក្រយាស្ងោយដ៏ឧត្តម ជាកត្តនៃស្រូវសាលីដ៏វិចិត្រ លាយដោយសាច់ដ៏ស្អាត ចំពោះព្រះអង្គនោះ ដោយសេចក្តីស្រឡាញ់ ។*

តំ ត្វំ កត្តំ បដិគ្គយ្ហ, ព្រាហ្មណស្ស អទាសយិ;
អត្តានំ អនសិត្វាន, កោយំ ធម្មោ នមត្ថុ តេ។

*ព្រះអង្គទទួលក្រយាស្ងោយនោះហើយ តែមិនសោយដោយព្រះអង្គឯង ត្រឡប់ជាប្រទានដល់ព្រាហ្មណ៍វិញ ខ្ញុំសូមក្រាបថ្វាយបង្គំចំពោះព្រះអង្គ តើការណ៍នេះជាសភាពដូចម្តេច ។*

( ព្រះរាជាត្រាស់ថា )

អាចរិយោ ព្រាហ្មណោ មយ្ហំ, កិច្ចាកិច្ចេសុ ព្យាវដោ;
គរុ ច អាមន្តនីយោ ច, ទាតុមរហាមិ ភោជនំ។

*ព្រាហ្មណ៍ (នេះ) ជាអាចារ្យរបស់យើង ជាអ្នកខ្វល់ខ្វាយ ក្នុងកិច្ចតូចនិងកិច្ចធំផង ជាបុគ្គលគួរគោរពផង គួរឲ្យយើងហៅរកផង (ព្រោះហេតុនោះ) យើងគួរឲ្យភោជន ។*

( កុដុម្ពិកៈពោលថា )

ព្រាហ្មណំ ទានិ បុច្ឆាមិ, គោតមំ រាជបូជិតំ;
រាជា តេ កត្តំ ចាទាសិ, សុចឹ មំសូបសេចនំ។

*ឥឡូវនេះ ខ្ញុំសូមសួរព្រាហ្មណ៍ ជាគោតមគោត្ត ដែលស្តេចតែងបូជា ព្រះរាជាបានប្រទានកត្ត ដែលលាយដោយសាច់ដ៏ស្អាត ដល់អ្នក ។*

តំ ត្វំ ភត្តំ បដិគ្គយ្ហ, ឥសិស្ស ភោជនំ អទា;
អខេត្តញ្ញាសិ ទានស្ស, កោយំ ធម្មោ នមត្ថុ តេ។

*អ្នកបានទទួលភត្តហើយ ក៏បានប្រគេននូវភោជនដល់ឥសីវិញ អ្នកប្រហែលជាដឹងថា ខ្លួនមិនមែនជាខេត្តនៃទាន ខ្ញុំសូមថ្វាយបង្គំចំពោះអ្នក តើការណ៍នេះជាសភាពដូចម្ដេច ។*

(ព្រាហ្មណ៍តបថា)

ភរាមិ បុត្តទារេ ច, ឃរេសុ គធិតោ អហំ;
ភុញ្ជេ មានុសកេ កាមេ, អនុសាសាមិ រាជិនោ។

*ខ្ញុំតែងចិញ្ចឹមកូននិងប្រពន្ធផង ជំពាក់ចិត្តក្នុងផ្ទះទាំងឡាយផង ប្រៀនប្រដៅព្រះរាជាថា សូមព្រះអង្គសោយនូវកាមទាំងឡាយ ជារបស់នៃមនុស្សផង ។*

អារញ្ញិកស្ស ឥសិនោ, ចិររត្តំ តបស្សិនោ;
វុឌ្ឍស្ស ភាវិតត្តស្ស, ទាតុមរហាមិ ភោជនំ។

*ហេតុនោះបានជាខ្ញុំប្រគេនភោជនដល់ឥសីវិញ ដែលនៅក្នុងព្រៃ មានតបៈអស់កាលវែង ចម្រើនដោយគុណ មានចិត្តចម្រើនហើយ ។*

(កុដុម្ពិកៈពោលថា)

ឥសិញ្ច ទានិ បុច្ឆាមិ, កិសំ ធមនិសន្ថតំ;
បរូឡ្ហកច្ឆនខលោមំ, បង្កទន្តំ រជស្សិរំ។

*ឥឡូវនេះ ខ្ញុំសូមសួរឥសី ដែលស្គមរីមរាមដោយសរសៃ មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល ។*

ឯកោ អរញ្ញេ វិហរសិ, ជាវកង្ខសិ ជីវិតំ;
ភិក្ខុ កេន តយា សេយ្យោ, យស្ស ត្វំ ភោជនំ អទា។

*លោកនៅក្នុងព្រៃម្នាក់ឯង មិនស្តាយជីវិត លោកបានប្រគេនភោជនដល់ភិក្ខុណា ភិក្ខុនោះប្រសើរជាងលោក ដោយគុណដូចម្តេច ។*

(តាបសតបថា)

ខណាន្តាលុកលម្ពានិ, ពិលាលិតក្កលានិ ច;
ធុនំ សាមាកនីវារំ, សង្ឃារិយំ បសារិយំ។

*អាត្មាជីកដំឡូងឈ្មោះអាលុកលម្ពៈ និងខណន្តៈទាំងឡាយផង ដំឡូងឈ្មោះពិលាលិនិងតក្កលៈទាំងឡាយផង ប្រូតស្រងែនិងស្មៅ (យកមក) បែនបុក (បរិភោគ)ផង ។*

សាកំ ភិសំ មធុំ មំសំ, ពទរាមលកានិ ច;
តានិ អាហរិត្វា ភុញ្ជាមិ, អត្ថិ មេ សោ បរិគ្គហោ។

*នាំយកគ្រឿងអន្ទក់និងក្រអៅឈូក ទឹកឃ្មុំ សាច់ ពទ្រានិងកន្ទួតព្រៃ មកបរិភោគផង នោះជាកំណាន់របស់អាត្មា ។*

បចន្តោ អបចន្តស្ស, អមមស្ស សកិញ្ចនោ;
អនាទានស្ស សាទានោ, ទាតុមរហាមិ ភោជនំ។

*អាត្មាជាបុគ្គលដាំស្ល មានសេចក្តីខ្វល់ខ្វាយ មានសេចក្តីប្រកាន់នៅឡើយ គួរប្រគេនភោជនដល់ភិក្ខុដែលជាអ្នកមិនដាំស្ល មិនមានសេចក្តីប្រកាន់ ។*

(កុដុម្ពិកៈពោលថា)

កិក្ខុញា ធានិ បុច្ឆាមិ, តុណ្ហីមាសីន សុព្វតំ,
ភសិ តេ កត្តំ ចាធាសិ, សុចិំ មំសូបសេចនំ។

ឥឡូវនេះ ខ្ញុំសូមសួរភិក្ខុដែលអង្គុយស្ងៀមមានវត្តល្អ ដូចតទៅនេះ (ឥសី) បានប្រគេនកត្តដែលលាយដោយសាច់ដ៏ស្អាតដល់លោក ។

តំ ត្វំ កត្តំ បដិគ្គយ្ហ, តុណ្ហី កុញ្ជាសិ ឯកកោ;
ជាញ្ញំ កាញ្ចិ និមន្តេសិ, កោយំ ធម្មោ ឆមត្ថុ តេ។

លោកទទួលកត្តហើយ ក៏បរិភោគស្ងៀមៗ ម្នាក់ឯង មិនបានអញ្ជើញបុគ្គលដទៃណាមួយ (ឲ្យបរិភោគផង) ឡើយ ខ្ញុំសូមថ្វាយបង្គំចំពោះលោក តើការណ៍នេះជាសភាពដូចម្តេច ។

(ព្រះបច្ចេកពុទ្ធសម្តែងថា)

ន បចាមិ ន ចាចេមិ, ន ចិន្ទាមិ ន ចេទយេ;
តំ មំ អកិញ្ចនំ ញត្វា, សព្វចាបេហិ អារតំ។

អាត្មាមិនដាំស្លខ្លួនឯង មិនប្រើឲ្យគេដាំស្ល មិនកាត់ខ្លួនឯង មិនប្រើគេឲ្យកាត់ ហេតុនោះបានជាឥសីដឹងថាអាត្មាជាអ្នកមិនមានសេចក្តីកង្វល់ ជាអ្នកប្រាសចាកបាបគ្រប់ជំពូក ។

វាមេន កិក្ខមាធាយ, ឧក្ខិណេន គាមណ្ឌលុំ;
ភសិ មេ កត្តំ ចាធាសិ, សុចិំ មំសូបសេចនំ។

ទើបកាន់ចង្ក្អាន់ដោយដៃឆ្វេង កាន់សម្បកឃ្លោកដោយដៃស្តាំ ហើយប្រគេនកត្តដែលលាយដោយសាច់ដ៏ស្អាតនោះដល់អាត្មា ។

ឯតេ ហិ ធាតុមរហន្តិ, សមមា សបរិគ្គហា;
បច្ចនីកមហំ មញ្ញេ, យោ ធាតារំ និមន្តយេ។

តាមពិត ជនទាំងឡាយ (មានស្តេចជាដើម) នុ៎ះ ជាអ្នកប្រកាន់ថារបស់អញ មាន សេចក្តីហួងហែង គួរតែឲ្យទាន (ដល់បុគ្គលប្រាកដស្មើដោយអាត្មា) បុគ្គលណា អញ្ជើញនូវអ្នកឲ្យទាន (មកបរិភោគ) អាត្មាសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកប្រតិបត្តិខុសទំនង ។

ពាក្យថា បុគ្គលណាអញ្ជើញនូវអ្នកឲ្យទាន (មកបរិភោគ) អាត្មាសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកប្រតិបត្តិខុសទំនង នេះមានសេចក្តីថា ការអញ្ជើញអ្នកឲ្យទានមកបរិភោគនេះ ឈ្មោះថាជា មិច្ឆាជីវបដិបទា ពោលគឺសម្រេចការចិញ្ចឹមជីវិត ដោយការស្វែងរកបិណ្ឌបាត ដោយអនេសនៈ ២១ យ៉ាងណាមួយ (ពាក្យទាំងនេះនិយាយចំពោះអ្នកបួស) ។

កុដុម្ពិកៈស្តាប់ពាក្យរបស់ព្រះបច្ចេកពុទ្ធហើយ មានចិត្តរីករាយ ពោលឧិសានគាថា ២ ថា

អត្ថាយ វត មេ អជ្ជ, ឥធាគច្ឆិ រថេសភោ;
សោហំ អជ្ជ បជានាមិ, យត្ថ ទិន្នំ មហប្ផលំ។

ក្នុងថ្ងៃនេះ ព្រះរាជាព្រះអង្គប្រសើរលើរថ បានយាងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំមែនហើយ ត្បិតខ្ញុំបានដឹងច្បាស់ ក្នុងថ្ងៃនេះថា ទានដែលគេឲ្យហើយ ចំពោះបុគ្គលណា ជាទានមានផលច្រើន ។

រដ្ឋេសុ គិទ្ធា រាជានោ, កិច្ចាកិច្ចេសុ ព្រាហ្មណា;
ឥសី មូលផលេ គិទ្ធា, វិប្បមុត្តា ច ភិក្ខវោ។

ស្តេចទាំងឡាយ ជាប់ជំពាក់ក្នុងផែនដី ពួកព្រាហ្មណ៍ជាប់ជំពាក់ ក្នុងកិច្ចតូចនិងកិច្ចធំ ពួកឥសី ជាប់ជំពាក់ក្នុងមើមឈើ និងផ្លែឈើ ឯពួកភិក្ខុទើបរួចស្រឡះចាកកិលេស ។

ពាក្យថា ពួកភិក្ខុ សេចក្តីថា ពួកភិក្ខុដែលជាព្រះបច្ចេកពុទ្ធទាំងឡាយ ជាអ្នករួចផុតចាកភពទាំងពួង ។

ព្រះបច្ចេកពុទ្ធសម្ដែងធម៌ដល់កុដុម្ពិកៈនោះ ហើយទៅកាន់លំនៅរបស់ខ្លួន តាបសក៏យ៉ាងនោះ ។ ចំណែកព្រះរាជាគង់នៅក្នុងសម្នាក់កុដុម្ពិកៈនោះអស់ពីរបីថ្ងៃហើយ ក៏ទៅកាន់នគរពារាណសីវិញ ។

ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ ដែលបិណ្ឌបាតប្រព្រឹត្តទៅដល់អ្នកសមគួរនោះ សូម្បីកាលមុន ក៏ប្រព្រឹត្តទៅដែរ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា

**តទា កុដុម្ពិកោ ធម្មរតនស្ស សក្ការការកោ កុដុម្ពិកោ អហោសិ** កុដុម្ពិកៈក្នុងកាលនោះបានមកជាកុដុម្ពិកៈដែលធ្វើសក្ការៈដល់ព្រះធម្មរតនៈ

**រាជា អានន្ទោ** ព្រះរាជាបានមកជាអានន្ទ

**បុរោហិតោ សារិបុត្តោ** បុរោហិតបានមកជាសារីបុត្រ

**ហិមវន្តតាបសោ បន អហមេវ អហោសិំ** ចំណែកតាបសក្នុងព្រៃហិមពាន្ត គឺតថាគតនេះឯង ។

ចប់ ភិក្ខាបរម្បរជាតក ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដលេក ៦០ ទំព័រ ៥៧)

ថ្ងៃអាទិត្យ ៥ កើត ខែមបឋមាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ១៧ ខែ មិថុនា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ.